**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះសីហនុ**

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងរដ្ឋប្បវេណីលេខ២៣៨

ចុះថ្ងៃទី០៥.១១.២០១៩

សាលក្រមលេខៈ ៧៥/០៥(ញ)

ចុះថ្ងៃទី១៣.១១.២០២០

**បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ សាលក្រមប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០។**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ។

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ។

**រវាង** ដើមចោទក្រុមហ៊ុន [redacted] អាសយដ្ឋានបច្ចុប្បន្ន [redacted] ដែលមានតំណាង [redacted]។

-មេធាវីតំណាងដោយអាណត្តិលោក [redacted] និងលោកស្រី [redacted]។

**និង** សហចុងចម្លើយៈ

១.ឈ្មោះ [redacted] XIANGBIAO ភេទប្រុស អាយុ ៤២ឆ្នាំ សញ្ជាតិចិន ជាតំណាង [redacted] អាស័យដ្ឋាននៅ [redacted]។

២.ឈ្មោះ [redacted] YUNBO ភេទប្រុស សញ្ជាតិចិន ជាតំណាង [redacted]។

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញៈ**

ក-បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើម នៃសេវាម៉ៅការសំណង់លើគម្រោងខ្ទង់គ្រឹះចំនួន១៣២,៦០០ (ដប់បីម៉ឺនពីរពាន់ប្រាំមួយរយ)ដុល្លារអាមេរិក និងសេវាខ្ទង់គ្រឹះចំនួន៣៥,៥៦០(បីម៉ឺនប្រាំពាន់ប្រាំរយហុកសិប) ដុល្លារអាមេរិកសរុបចំនួន១៦៨,១៦០(ដប់ប្រាំមួយម៉ឺនប្រាំបីពាន់មួយរយហុកសិប)ដុល្លារអាមេរិកឲ្យទៅដើមចោទ។

ខ-បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់០,៥%(សូន្យក្បៀសប្រាំ)ភាគរយ ក្នុងមួយថ្ងៃនៃការបង់ប្រាក់យឺតយ៉ាវចំនួន១៨២,៩៨៨(ដប់ប្រាំបីម៉ឺនពីរពាន់ប្រាំបួនរយប៉ែតសិបប្រាំបី)ដុល្លារអាមេរិក ដូចមានចែងក្នុងកិច្ចសន្យាម៉ៅការបន្តសំណង់គម្រោងគ្រឹះសសរអាគារ [redacted] ឲ្យទៅដើមចោទ។

គ-បង្គាប់ឲ្យសហចុងចម្លើយសងថ្លៃអាត្រាការប្រាក់តាមច្បាប់ចំនួន១៨%(ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំនៃសេវាកម្មម៉ៅការសំណង់ និងសេវាខ្ទង់គ្រឹះ ឲ្យទៅដើមចោទ គិតចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទ នៃសាលក្រមចូលជាស្ថាពរ។

ឃ-បង្គាប់ឲ្យសហចុងចម្លើយសងសោហ៊ុយ រឹបអូសរថយន្ត សោហ៊ុយថែទាំរថយន្ត សោហ៊ុយចុះបញ្ជីផ្ទុកផ្ដាក់រថយន្ត និងសោហ៊ុយចំណាយផ្សេងៗលើរថយន្ត ជាវត្ថុរឹបអូសយកដើម្បីធានាលើបំណុលចំនួន១៥,០០០ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ឲ្យទៅដើមចោទ។

ង-បង្គាប់ឲ្យសហចុងចម្លើយចេញថ្លៃសេវាកម្មមេធាវីចំនួន៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក។

ច-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ។

ឆ-សាលក្រមនេះអាចអនុវត្ត ជាបណ្ដោះអាសន្នបាន។

## អង្គហេតុ និងចំណុចវិវាទ

**១-អង្គហេតុ**

កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ [redacted]បាន ចុះកិច្ចសន្យាម៉ៅការបន្តសំណង់គម្រោងគ្រឹះសសរអាគារជាមួយ[redacted] ដែលមានឈ្មោះ[redacted] XiangBiao និងឈ្មោះ[redacted] Yunbo ជាអ្នកតំណាងសាងសង់អាគារឈ្មោះ[redacted]មានទីតាំងស្ថិតនៅភូមិ៣ [redacted] ក្រុង[redacted] ក្នុងតម្លៃទឹកប្រាក់ចំនួន២១៥,០០០ដុល្លារអាមេរិក។ ក្រោយពីចុះកិច្ចព្រមព្រៀងរួចហើយ[redacted] បានបំពេញកាតព្វកិច្ចរបស់ខ្លួនរួចរាល់អស់ហើយតាមកិច្ចសន្យាខាងលើ។ ផ្ទុយទៅវិញ ក្រុមហ៊ុន[redacted] បានទូទាត់ប្រាក់ឲ្យដើមចោទបានចំនួនពីរលើកសរុបទឹកប្រាក់ស្មើនឹង៨២,៤០០(ប្រាំបីម៉ឺនពីរពាន់បួនរយ)ដុល្លារអាមេរិកប៉ុណ្ណោះ។ លុះមកដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ក្រុមហ៊ុន[redacted] បានធ្វើកិច្ចសន្យាសងប្រាក់ជំពាក់តាមដំណាក់កាលឲ្យមក[redacted]តាមកិច្ចសន្យា ចុះថ្ងៃទីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ តែសហចុងចម្លើយនៅតែមិនបានសងប្រាក់ជំពាក់ឲ្យមកក្រុមហ៊ុនខ្វង់គ្រឹះកោះពេជ្រ រហូតដល់សព្វថ្ងៃនេះ។

**២-សេចក្ដីថ្លែងការណ៍របស់ភាគី**

-មេធាវីហួត [redacted] តំណាងដោយអាណត្តិឲ្យដើមចោទធ្វើសេចក្ដីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថាៈ ខ្លួនសូមរក្សាទុកសេចក្ដីថ្លែងការណ៍ដូចមាននៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ទុកទាំងស្រុង។ ម្យ៉ាងវិញទៀត កូនក្ដីខ្លួនទទួលដំណឹងពីការចូលរួមនីតិវិធីនាពេលនេះរួចហើយ។

-សហចុងចម្លើយឈ្មោះ[redacted]GBIAO និងឈ្មោះ[redacted] YUNBO បានអវត្តមាននៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង១៤ និង៣០ នាទីរសៀល បើទោះបីជាបានទទួលដំណឹងតាមដីកាកោះ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ និងលិខិតជូនដំណឹងអំពីការបញ្ជូនតាមការផ្សាយជាសាធារណៈលេខៈ៩៦៦៨ រប/២០ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ត្រឹមត្រូវតាមនីតិវិធីច្បាប់រួចហើយ។

-ការពិនិត្យភស្តុតាងជាឯកសាររួមមានៈ

១-កិច្ចសន្យាម៉ៅការបន្តសំណង់រវាង[redacted] ជាមួយក្រុមហ៊ុន[redacted] ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨។

២-ប័ណ្ណដាក់ប្រាក់ចូលគណនី(ដុល្លារ)របស់ធនាគារកាណាឌីយ៉ា គ.អ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨។

៣-ប័ណ្ណដាក់ប្រាក់ចូលគណនី(ដុល្លារ)របស់ធនាគារកាណាឌីយ៉ា គ.អ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

៤-កិច្ចព្រមព្រៀងទូទាត់បំណុលរវាង[redacted] តំណាងដោយឈ្មោះ[redacted] BIAO ជាមួយ[redacted] ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩។

-មេធាវីហួត [redacted] បានធ្វើសេចក្ដីថ្លែងការណ៍បញ្ជាក់ថាៈ ខ្លួនសំណូមពរចុងក្រោយដូចការទាមទារនៅក្នុងពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ហើយការទាមទារចំណុច(ក)ផ្អែកទៅលើកិច្ចសន្យាម៉ៅ

ការបន្តសំណង់រវាង[redacted] ជាមួយក្រុមហ៊ុន[redacted] ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨។ រីឯ ការទាមទារចំណុច(ខ)ផ្អែកទៅលើប្រការ២ ត្រង់ចំណុចទី៤ នៃកិច្ចសន្យាម៉ៅការបន្តសំណង់រវាង[redacted] ជាមួយក្រុមហ៊ុន[redacted] ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨។ ចំពោះការទាមទារចំណុច(គ) មិនមានចែងនៅក្នុងកិច្ចសន្យានោះទេតែយោងទៅតាមក្រមរដ្ឋប្បវេណី។ ដោយឡែកចំពោះការទាមទារត្រង់ចំណុច(ឃ) គឺខ្លួនសុំឈប់ប្ដឹងទាមទារវិញហើយ ដោយសារចំណុចនេះកូនក្ដីខ្លួនបានអនុវត្តដោយបង្ខំសម្រេចលើការទាមទារនេះរួចហើយ។

-មេធាវីសេង [redacted] តំណាងដោយអាណត្តិឲ្យដើមចោទថ្លែងការណ៍បញ្ជាក់ថា៖ ខ្លួនសូមឯកភាពចំពោះការលើកឡើងរបស់មេធាវីហួត [redacted] ទាំងស្រុងដោយគ្មានអ្វីបន្ថែមទេ។

**៣-ចំណុចវិវាទ៖** គ្មាន។

## **សំអាងហេតុ**

១/ឆ្លងតាមសេចក្ដីថ្លែងការណ៍នាពេលទាញហេតុផលដោយផ្ទាល់មាត់របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ និងតាមការពិនិត្យភស្តុតាងជាឯកសារនូវ៖ កិច្ចសន្យាម៉ៅការបន្តសំណង់គម្រោងគ្រឹះសសរអាគារ [redacted]HUA ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ រវាងក្រុមហ៊ុន[redacted] និងក្រុមហ៊ុន[redacted]ឃើញថា៖ គូភាគីពិតជាមានឆន្ទៈពិតប្រាកដក្នុងការបង្កើតកិច្ចសន្យា ដោយបានព្រមព្រៀងបំពេញករណីយកិច្ចរបស់ខ្លួនរៀងៗខ្លួន ដោយគ្មានការបង្ខិតបង្ខំ គ្មានវិការៈ ហើយគូភាគីនៃកិច្ចសន្យាជាសមត្ថជនស្របតាមមាត្រា៣១១ និងមាត្រា៦៥២ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

២/តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឃើញថា៖ កូនក្ដីខ្លួនបានទទួលម៉ៅការបន្តសំណង់គ្រឹះគម្រោងសសរអាគារ [redacted]HUA ជាមួយសហចុងចម្លើយក្នុងតម្លៃ១៥,០០០ (ម្ភៃមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិកដែលការថ្លែងការណ៍នេះមានភាពស៊ីចង្វាក់ជាមួយកិច្ចសន្យាម៉ៅការបន្តសំណង់គម្រោងគ្រឹះសសរអាគារ [redacted] HUA ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ត្រង់ប្រការ១ ដែលអាចឲ្យតុលាការជឿជាក់បាន។ម្យ៉ាងទៀត មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍បន្ថែមទៀតថា៖ ក្រោយពេលចុះកិច្ចសន្យាម៉ៅការបន្តសំណង់គ្រឹះគម្រោងសសរអាគារ [redacted] HUA រួចហើយ គឺកូនក្ដីខ្លួនបានបំពេញករណីយកិច្ចរបស់ខ្លួនតាមកិច្ចសន្យារួចរាល់អស់ហើយ។ ផ្ទុយទៅវិញ សហចុងចម្លើយទើបតែបានទូទាត់ប្រាក់ឲ្យមកកូនក្ដីខ្លួនចំនួនពីរលើកប៉ុណ្ណោះ៖ សរុបទឹកប្រាក់ចំនួន ៨២,៤០០(ប្រាំបីម៉ឺនពីរពាន់បួនរយ) ដុល្លារអាមេរិក ដែលស៊ីចង្វាក់ជាមួយការពិនិត្យភស្តុតាងជាឯកសារនូវ៖ បុលប្បទានប័ត្រចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ នូវទឹកប្រាក់ចំនួន ៦៤,៥០០(ប្រាំមួយម៉ឺនបួនពាន់ប្រាំរយ)ដុល្លារអាមេរិក និងមូលប្បទានប័ត្រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ នូវទឹកប្រាក់ចំនួន ១៧,៩០០(មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយ)ដុល្លារអាមេរិក។ ហេតុនេះ តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ និងការពិនិត្យភស្តុតាងជាឯកសារខាងលើឃើញថា៖ សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទសរុបចំនួន ១៣២,៦០០(ដប់បីម៉ឺនពីរពាន់ប្រាំមួយរយ)ដុល្លារអាមេរិក។ បន្ថែមលើសពីនេះទៀត មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍ថា៖ សហចុងចម្លើយបានជំពាក់ប្រាក់ថ្លៃខូចគ្រឹះកូនក្ដីខ្លួននៅកន្លែងការងារផ្សេងទៀតសរុបទឹកប្រាក់ចំនួន ៣៥,៥៦០(បីម៉ឺនប្រាំពាន់ប្រាំរយហុកសិប)ដុល្លារអាមេរិក និងបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ដើម្បីទូទាត់

បំណុលឲ្យមកកូនក្តីខ្លួនទៀតផង។ សរុបជារួមមកឃើញថាៈ ចំនួនទឹកប្រាក់ដែលសហចុងចម្លើយនៅជំពាក់ដើមចោទ មានចំនួនទឹកប្រាក់សរុប ១៦៨,១៦០(ដប់ប្រាំមួយម៉ឺនប្រាំបីពាន់មួយរយហុកសិប)ដុល្លារអាមេរិក។ រីឯ សហចុងចម្លើយបានអវត្តមាននាពេលទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ទោះបីជាតុលាការបញ្ជូនដីកាកោះឲ្យចូលរួមនីតិវិធីត្រឹមត្រូវតាមរួចហើយក៏ដោយ។ ដូច្នេះ ការអវត្តមានរបស់សហចុងចម្លើយត្រូវចាត់ទុកថាសហចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការប្តឹងទាមទារ។ គប្បី តុលាការទទួលស្គាល់លើប្រាក់ជំពាក់ដើមចោទដែលសហចុងចម្លើយនៅខ្វះសរុបចំនួន ១៦៨,១៦០(ដប់ប្រាំមួយម៉ឺនប្រាំបីពាន់មួយរយហុកសិប)ដុល្លារអាមេរិក ស្របតាមមាត្រា១២៣ និងមាត្រា២០១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៦៥៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៣.ចំពោះការទាមទាររបស់ដើមចោទ ឲ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ០,៥% ក្នុង១ថ្ងៃ នៃការបង់ប្រាក់យឺតយ៉ាវ នៃការប្រាក់ជំពាក់តាមកិច្ចសន្យា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ត្រង់ប្រការ២ ចំណុច៤ ចំនួន ១៣២,៦០០(ដប់បីម៉ឺនពីរពាន់ប្រាំមួយរយ)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ រហូតដល់ត្រឹមថ្ងៃដាក់ពាក្យបណ្តឹង ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ដែលស្មើនឹងទឹកប្រាក់ចំនួន ១៨២,៩៨៨(ដប់ប្រាំបីម៉ឺនពីរពាន់ប្រាំបួនរយប៉ែតសិបប្រាំបី)ដុល្លារអាមេរិក ដូចមាននៅក្នុងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ គប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤.ចំពោះការទាមទាររបស់ដើមចោទ ឲ្យសហចុងចម្លើយសងថ្លៃអាត្រាការប្រាក់ចំនួន១៨%ក្នុងមួយឆ្នាំ នៃថ្លៃសេវាម៉ៅការសំណង់ និងសេវាខូចគ្រឹះ គិតចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទនៃសាលក្រមចូលជាស្ថាពរឃើញថាៈ គូភាគីមិនបានព្រមព្រៀងក្នុងការកំណត់អត្រាការប្រាក់ក្នុងកិច្ចសន្យាម៉ៅការបោះសំណង់គម្រោងគ្រឹះសសរអាគារ [redacted] HUA ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ នោះទេ។ ផ្ទុយទៅវិញ ទំនាក់ទំនងគតិយុត្តរបស់គូភាគីក្នុងការបង្កើតកិច្ចសន្យានេះ គឺមានសញ្ញាណជាកាតព្វកិច្ចបង្កើតការប្រាក់តាមការកំណត់ដោយច្បាប់។ គប្បី តុលាការពិចារណាលើការទាមទារត្រង់ចំណុចអត្រាការប្រាក់របស់ដើមចោទ ស្របតាមមាត្រា៣១៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ រីឯ ការទាមទាររបស់ដើមចោទឲ្យសហចុងចម្លើយសងសោហ៊ុយរើបរូសរថយន្ត សោហ៊ុយថែទាំរថយន្ត សោហ៊ុយថែចុះបញ្ជីផ្ទុកផ្ទាត់រថយន្ត និងសោហ៊ុយចំណាយផ្សេងៗចំនួន១៥,០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក គឺដើមចោទបានសុំឈប់ប្តឹងទាមទារវិញហើយ ដោយដើមចោទបានអនុវត្តដោយបង្ខំសម្រេចពីសិទ្ធិទាមទាររបស់ខ្លួនរួចហើយ។ គប្បី តុលាការមិនលើកយកមកពិចារណាឡើយ។

៥-ចំពោះការទាមទាររបស់ដើមចោទឲ្យសហចុងចម្លើយសងការខូចខាតពេលវេលា និងសេវាកម្មមេធាវី ចំនួន ៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក ដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាបណ្តាលឲ្យដើមចោទខាតបង់ពេលវេលា និងសោហ៊ុយចំណាយផ្សេងៗ។ គប្បី តុលាការពិចារណាទៅតាមស្ថានភាពជាក់ស្តែង ដោយធៀបជាមួយព្យសនកម្មដែលដើមចោទបានទទួលរងការខូចខាត។

៦-ការប្តឹងសុំរបស់ដើមចោទឲ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន គឺមានមូលហេតុត្រឹមត្រូវ ស្របតាមមាត្រា១៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ គប្បី តុលាការសម្រេចអនុញ្ញាតប្រកាសឲ្យអនុវត្តបណ្តោះអាសន្នអំពីការទាមទារត្រង់ចំណុចប្រាក់ជំពាក់ចំនួន ១៦៨,១៦០(ដប់ប្រាំមួយម៉ឺនប្រាំបីពាន់មួយរយហុកសិប)ដុល្លារអាមេរិក។

៧-ប្រាក់ប្រាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី តាមមាត្រា៦៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្ដីសម្រេចបញ្ចប់

១-ទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយបង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ឲ្យដើមចោទនូវ៖

ក.ប្រាក់ចំនួន ១៦៨,១៦០(ដប់ប្រាំមួយម៉ឺនប្រាំបីពាន់មួយរយហុកសិប)ដុល្លារអាមេរិក។

ខ.ការប្រាក់ចំនួន ០,៥%(ប្រាំភាគរយ)ក្នុង ១ថ្ងៃ នៃការបង់ប្រាក់យឺតយ៉ាវនៃការប្រាក់ជំពាក់តាមកិច្ចសន្យា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ត្រង់ប្រការ២ ចំណុច៤ ចំនួន ១៣២,៦០០(ដប់បីម៉ឺនពីរពាន់ប្រាំមួយរយ)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ រហូតដល់ត្រឹមថ្ងៃដាក់ពាក្យបណ្ដឹង ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ សរុបចំនួន ១៨២,៩៨៨(ដប់ប្រាំបីម៉ឺនពីរពាន់ប្រាំបួនរយប៉ែតសិបប្រាំបី)ដុល្លារអាមេរិក។

គ.អត្រាការប្រាក់ចំនួន ៥%(ប្រាំភាគរយ)ក្នុងមួយឆ្នាំ នៃថ្លៃសេវាម៉ៅការសំណង់ និងសេវាខូចខាត គិតចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទនៃសាលក្រមចូលជាស្ថាពរ។

ឃ.ប្រាក់ថ្លៃសេវាកម្មមេធាវីចំនួន ១០(ដប់)លានរៀល។ ការទាមទារលើសពីនេះច្រានចោល។

២-សាលក្រមនេះមានអានុភាពអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី(១-ក) នៃសេចក្ដីសម្រេចបញ្ចប់។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

ចៅក្រម

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

នៅភ្នំពេញ ថ្ងៃទី១៣ ខែ១១.....ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]